# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## អំពាវនាវឲ្យមានការរៀបចំការបោះឆ្នោតឡើងវិញមុនបញ្ចប់អាណត្តិ

បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការអត់ធ្មត់របស់បាតុករ អាជ្ញាធរ និងគណបក្សនយោបាយទាំងពីរដែលមិនបានប្រើហិង្សាក្នុងដំណើរការដោះស្រាយវិបត្តិនយោបាយនាពេលបច្ចុប្បន្ន ហើយបាន នឹងកំពុងខិតខំបន្តការចរចា។

ដោយសង្កេតឃើញគោលជំហរបស់គណបក្សនយោបាយជាប់ឆ្នោតទាំងពីរ គឺគណបក្សប្រជាជនកម្ពុជាដែលមានឆន្ទៈចង់កំណែទំរង់ប្រព័ន្ធបោះឆ្នោតសម្រាប់រៀបចំការបោះឆ្នោតពេលចប់អាណត្តិ និងគណបក្សសង្គ្រោះជាតិដែលចង់កំណែទំរង់ប្រព័ន្ធបោះឆ្នោតសម្រាប់រៀបចំការបោះឆ្នោតឡើងវិញភ្លាម បន្ទប់ស្ថានការណ៍យល់ឃើញថា គណបក្សនយោបាយទាំងពីរ មានជំហរដូចគ្នាដោយជ្រើសរើសការបោះឆ្នោតជាមធ្យោបាយដើម្បីដោះស្រាយវិបត្តិនយោបាយ។ ម្យ៉ាងវិញទៀត បើភាគីណាមួយទទួលបានជ័យជំនះក្នុងការដណ្តើមអំណាចដោយប្រើកម្លាំងហិង្សាតាមរយៈប្រជាពលរដ្ឋ ឬការបង្ក្រាបដោយកងប្រដាប់អាវុធ/យោធា រដ្ឋាភិបាលមួយនោះនៅតែគ្មាននីត្យានុកូលភាពដដែល។ ដូចនេះ ក្នុងករណីការចរចាមិនទទួលបានដំណោះស្រាយនយោបាយ បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល សូមផ្តល់អនុសាសន៍ឲ្យគណបក្សនយោបាយទាំងពីរជ្រើសរើសការរៀបចំការបោះឆ្នោតឡើងវិញមុនបញ្ចប់អាណត្តិ ក្រោយពេលដែលកំណែទម្រង់នៃការបោះឆ្នោតបានបញ្ចប់រួចរាល់ ដែលជាជម្រើសល្អបំផុត។

ដើម្បីឲ្យការបោះឆ្នោតឡើងវិញនេះដោយសេរី និងយុត្តិធម៌ គេចាំបាច់ត្រូវការពេលវេលាដើម្បីធ្វើកំណែទម្រង់ការបោះឆ្នោត។ បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល យល់ឃើញថា ច្បាប់ នីតិវិធី និងយន្តការទាក់ទិននឹងការបោះឆ្នោត គួរត្រូវបានបង្កើត និងកែលម្អឡើងវិញរួមមាន៖

- កំណែទម្រង់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គ្រប់លំដាប់ថ្នាក់ និងក្រុមប្រឹក្សាធម្មនុញ្ញ (រួមទាំងសមាសភាព រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច)។
- កែលម្អប្រព័ន្ធផ្សព្វផ្សាយ ពិសេសទូរទស្សន៍ និងវិទ្យុ ដោយមានគោលនយោបាយ និងគោលការណ៍សមធម៌ តុល្យភាព និងសេរីសម្រាប់ការទទួលបានការប្រើប្រាស់ និងការផ្សព្វផ្សាយ។
- ផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះ និងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលអាចកំណត់បានអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ និងមានប័ណ្ណបោះឆ្នោត។
- កំណែទម្រង់យន្តការដោះស្រាយទំនាស់វិវាទ និងបណ្តឹងបោះឆ្នោតឱ្យឯករាជ្យរួមមាន ការបង្កើតយន្តការប្រសិទ្ធិភាពមួយសម្រាប់ការអង្កេតភាពមិនប្រក្រតី។
- មានច្បាប់ ដើម្បីតម្លាភាពហិរញ្ញវត្ថុ និងកំណត់ការចំណាយរបស់គណបក្សនយោបាយក្នុងដំណើរការឃោសនាបោះឆ្នោត។
- ពង្រឹងការអនុវត្តន៍ច្បាប់ឲ្យបានពេញលេញអំពីភាពអព្យាក្រឹត្យ មិនលម្អៀងដាច់ខាតសម្រាប់ទាំងស្ថាប័ន និងមន្ត្រីនៃកងយុទ្ធពលខេមរភូមិន្ទ នគរបាល និងមន្ត្រីតុលាការ។
- មានច្បាប់ ឬ/និងគោលនយោបាយដើម្បីកំណត់កូតាស្ត្រីជាតំណាងជាប់ឆ្នោត។

ការបោះឆ្នោតឡើងវិញមុនបញ្ចប់អាណត្តិ គួរគប្បីត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៥យ៉ាងយូរ ដោយសារគេត្រូវការពេលវេលា ដើម្បីអនុវត្តកំណែទម្រង់ការបោះឆ្នោតដែលអាចធានាឲ្យមាន លក្ខខណ្ឌអប្បបរមាសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងបញ្ចៀសទំនាស់បោះឆ្នោត និងវិបត្តិនយោបាយនាពេលខាងមុខ។

បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល និងសម្ព័ន្ធកំណែទម្រង់បោះឆ្នោតបាន និងកំពុងត្រៀមខ្លួនផ្តល់កិច្ចសហការគាំទ្រ និងចូលរួមក្នុងយន្តការកំណែទម្រង់ការបោះឆ្នោត។

បន្ទប់ស្ថានការណ៍នៃអង្គការសមាគមមិនមែនរដ្ឋាភិបាល ស្នើសុំឲ្យអាជ្ញាធរ និងថ្នាក់ដឹកនាំគណបក្សនយោបាយបន្តអត់ធ្មត់ និងពិភាក្សាដោះស្រាយបញ្ហាជម្លោះដោយសន្តិវិធី ដើម្បីឈានដល់ការព្រមព្រៀងរៀបចំការបោះឆ្នោតឡើងវិញមុនបញ្ចប់អាណត្តិ។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| ១. លោក ធន សារាយ | ប្រធាននៃសមាគមអាដហុក&ខុមហ្វ្រែល | ០១៦ ៤៤ ០០ ៤៤ |
| ២. លោកស្រី ធីតា យឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |

| | | |
|---|---|---|
| ៥. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៦. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៧. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ០៨. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ០៩. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១០. លោក ម៉ាក ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ១១. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១២. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៣. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ១៤. លោក ហ៊ឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ១៥. លោក ណែប ស៊ិនថៃ | នាយកAPI | ០១២ ៥២ ៧០ ០៤ |
| ១៦. លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិDPA | ០១២ ៧៧ ៩៧ ៣៤ |
| ១៧. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |
| ១៨. លោកបណ្ឌិត កែម ឡី | អ្នកវិភាគឯករាជ្យ | ០១២ ៧៨ ៧០ ៨៤ |
| ១៩. លោកបណ្ឌិត ឡៅ ម៉ុងហៃ | អ្នកវិភាគឯករាជ្យ | ០១២ ៤២ ៩៤ ១៦ |